**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ៧៤៩ សរណន.កសក

# សារាចរណែនាំ

# ស្តីពី

# ការពង្រីកសេវាព័ត៌មានទីផ្សារកសិកម្មដល់មូលដ្ឋានភូមិ-ឃុំ

***&***

មកទល់នឹងបច្ចុប្បន្ននេះ សេវាព័ត៌មានទីផ្សារកសិកម្ម ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានប្រតិបត្តិកន្លងមក ត្រូវបានវាយតម្លៃខ្ពស់ក្នុងការបំពេញតួនាទី ជួយធ្វើឱ្យកសិករមានមូលដ្ឋានត្រឹមត្រូវ ក្នុងការធ្វើផែនការផលិតកម្មរបស់គាត់ និងសម្រេចជោគជ័យក្នុងផលិតកម្មកសិកម្ម ដែលឆ្លើយតបទៅនឹងតម្រូវការរបស់ទីផ្សារ សម្រួលដល់កសិករក្នុងការចរចាថ្លៃ និងអាចសម្រេចចិត្តលក់ផលិតផលឱ្យឈ្មួញនៅលើទីផ្សារ ស្របតាមកាលានុវត្តិភាព ដែលអាចប្រមូលប្រាក់ចំណូលខ្ពស់ពីផលិតកម្មរបស់ខ្លួន ។ សេវាព័ត៌មានទីផ្សារកសិកម្ម ក៏បានជួយផងដែរដល់ពាណិជ្ជករ ឱ្យទទួលបានផលចំណេញ ក្នុងការសម្រេចចិត្តបញ្ជូនទំនិញ ពីកន្លែងដែលមានទំនិញច្រើនលើសលុប ទៅកាន់ទីផ្សារដែលត្រូវការ និងអាចធ្វើការសម្រេចចិត្តស្តុកឬលក់ទំនិញ ដើម្បីទទួលបានប្រាក់ចំណេញខ្ពស់។

កន្លងមក សេវាព័ត៌មានទីផ្សារកសិកម្ម ដែលក្រសួងអនុវត្ត បានគ្របដណ្តប់លើ រាជធានី ខេត្ត ចំនួន ១១ រួមមាន: រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តតាកែវ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តព្រះសីហនុ ខេត្តបន្ទាយមានជ័យ ខេត្តកំពត ខេត្តកំពង់ឆ្នាំង និង ខេត្តព្រៃវែង និងបានធ្វើការផ្សព្វផ្សាយតាមរយៈវិទ្យុចំនួន ៨ ផ្សព្វផ្សាយព័ត៌មានទីផ្សារកសិកម្ម តាមសេវាផ្ញើសារជាអក្សរ (Short Message Service-SMS) ព្រឹត្តិបត្រព័ត៌មានទីផ្សារកសិកម្ម និងការផ្សព្វផ្សាយតាមប្រព័ន្ធវេបសាយ ។ ដោយសារថា កសិករភាគច្រើននៅតែត្រូវការព័ត៌មានទីផ្សារកសិកម្ម ពិសេសប្រជាកសិករតាមបណ្តាភូមិ-ឃុំ ដាច់ស្រយាលនៅជនបទទូទាំងប្រទេស ការងារនេះ ទាមទារឱ្យមានការពង្រីកបន្ថែមទៀត។

ដូចនេះ ក្នុងទិសដៅនិងយុទ្ធសាស្ត្រយូរអង្វែង សំដៅធ្វើឱ្យប្រសើរឡើងនូវកំរិតជីវភាពរស់នៅរបស់ប្រជាកសិករនៅទូទាំងប្រទេស តាមរយៈនៃការផ្តល់ព័ត៌មានទីផ្សារកសិកម្ម ឱ្យបានដល់គ្រប់មូលដ្ឋានភូមិ-ឃុំ ដោយប្រើប្រាស់គ្រប់មធ្យោបាយ និងរូបភាពចាត់តាំងនានា ពិសេសប្រព័ន្ធឃោសនា

តាមលោកធាតុអាកាស និងតាមរយៈ មន្ទីរកសិកម្មរាជធានី ខេត្ត ការិយាល័យកសិកម្ម ក្រុង ស្រុក ខណ្ឌ និងបណ្តាញភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ ទូទាំងប្រទេសនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សូមធ្វើការណែនាំដល់គ្រប់អង្គភាពជំនាញថ្នាក់កណ្តាល មន្ទីរកសិកម្មរាជធានី ខេត្ត ទូទាំងប្រទេស ត្រូវជម្រុញអនុវត្តនូវសកម្មភាពជាក់ស្តែងមួយចំនួនចំពោះមុខ ដូចខាងក្រោម :

១. នាយកដ្ឋានផែនការ និងស្ថិតិ ត្រូវបន្តនិងពង្រីកសកម្មភាពប្រមូល និងផ្សព្វផ្សាយព័ត៌មានទីផ្សារកសិកម្ម ដោយរួមជាមួយមន្ត្រីទីផ្សារកសិកម្មនៅទូទាំង២៤រាជធានី ខេត្ត។ ត្រូវបន្តនិងពង្រីកការផ្សព្វផ្សាយតាមវិទ្យុ និងរៀបចំចងក្រងព្រឹត្តិបត្រព័ត៌មានទីផ្សារកសិកម្មប្រចាំខែ-ប្រចាំឆ្នាំ និង បោះពុម្ពសម្រាប់ការចែកផ្សាយ ដល់អង្គភាពជំនាញថ្នាក់កណ្តាល មន្ទីរកសិកម្មរាជធានី ខេត្ត និងការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ។

២. នាយកដ្ឋានផែនការ និងស្ថិតិ ត្រូវរៀបចំផែនការបង្កើនសមត្ថភាពមន្ត្រីរាជការ និង បើកវគ្គបណ្តុះបណ្តាល ក៏ដូចជាវគ្គបំពាក់បំប៉នជំនាញទីផ្សារកសិកម្ម ដល់មន្ត្រីទីផ្សារកសិកម្មនៃមន្ទីរកសិកម្មរាជធានី ខេត្ត ដើម្បីឱ្យមន្ត្រីទាំងនោះ អាចមានសមត្ថភាពក្នុងការអនុវត្តការងារផ្តល់សេវាព័ត៌មានទីផ្សារកសិកម្ម ។

៣. នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម ត្រូវយកចិត្តទុកដាក់និងចូលរួមក្នុងការផ្សព្វផ្សាយព័ត៌មានទីផ្សារកសិកម្ម ឱ្យដល់មូលដ្ឋានភូមិ-ឃុំ តាមរយៈបណ្តាញមន្ត្រីផ្សព្វផ្សាយកសិកម្មក្រុង ស្រុក ខណ្ឌ និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ ។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ត្រូវទំនាក់ទំនងនាយកដ្ឋានផែនការនិងស្ថិតិ ដើម្បីយកព័ត៌មានទីផ្សារកសិកម្ម និងបញ្ចូលទៅក្នុងកម្មវិធីផ្សាយតាមទូរទស្សន៍ជាតិកម្ពុជា រៀងរាល់សប្តាហ៍។

៤. មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម និង នាយកដ្ឋានផែនការនិងស្ថិតិ ត្រូវរួមសហការគ្នា ក្នុងការផ្សព្វផ្សាយព័ត៌មានទីផ្សារកសិកម្ម តាមរយៈគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឱ្យបានទៀងទាត់ និងធានាបច្ចុប្បន្នភាពនៃព័ត៌មានជាប្រចាំ។

៥. មន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់អនុវត្តខ្លឹមសារនៃលិខិតលេខ ២៧៤០ កសក ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការបង្កើតផ្នែក "ទីផ្សារកសិកម្ម" នៅចំណុះការិយាល័យផែនការ-គណនេយ្យរបស់មន្ទីរ និងត្រូវរៀបចំចាត់តាំងមន្ត្រីជំនាញទទួលបន្ទុកការងារនេះ ឱ្យបានច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការអនុវត្តការងារផ្នែកទីផ្សារកសិកម្ម ។

៦. មន្ទីរកសិកម្ម រាជធានី ខេត្ត ត្រូវជម្រុញអនុវត្ត និងបន្តការងារប្រមូលព័ត៌មានទីផ្សារកសិកម្ម រួចផ្សព្វផ្សាយនៅតាមស្ថានីយ៍វិទ្យុក្នុងខេត្តរបស់ខ្លួន។ ព័ត៌មានទីផ្សារកសិកម្ម

ដែលមន្ទីរកសិកម្មរាជធានី ខេត្ត ប្រមូលបាន ត្រូវបញ្ជូនទៅការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើការផ្សព្វផ្សាយបន្តដោយមន្ត្រីផ្សព្វផ្សាយក្រុង ស្រុក ខណ្ឌ តាមរយៈការបិទផ្សាយព័ត៌មានទីផ្សារនៅតាមក្តារខៀនផ្សព្វផ្សាយព័ត៌មានតាមឃុំ-សង្កាត់-ភូមិ។ ព័ត៌មានទីផ្សារកសិកម្ម ដែលមន្ទីរកសិកម្មរាជធានី ខេត្ត ប្រមូលបាន ក៏ត្រូវបញ្ជូនមកក្រសួង (នាយកដ្ឋានផែនការនិងស្ថិតិ) សម្រាប់បញ្ចូលក្នុងប្រព័ន្ធព័ត៌មានទីផ្សារកសិកម្ម និង ផ្សព្វផ្សាយបន្តតាមគ្រប់រូបភាព។

៧. នាយកដ្ឋានផែនការនិងស្ថិតិ និង មន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវរៀបចំលើកគំរោងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដោយប្រើប្រាស់ថវិកាជាតិ សម្រាប់គាំទ្រដល់ការអនុវត្តការងារ ផ្តល់សេវាព័ត៌មានទីផ្សារកសិកម្ម និងត្រូវសម្របសម្រួលកៀងគរជំនួយ ដើម្បីអនុវត្តផែនការសកម្មភាពសេវាព័ត៌មានទីផ្សារកសិកម្ម ឱ្យទទួលបានលទ្ធផលល្អ និង មានប្រសិទ្ធភាពខ្ពស់ ។

ទទួលបាននូវសារាចរណែនាំនេះ គ្រប់អង្គភាពជំនាញថ្នាក់កណ្តាល ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង គ្រប់មន្ទីរកសិកម្ម រាជធានី ខេត្ត ទូទាំងប្រទេស ត្រូវទទួលខុសត្រូវ ចាត់វិធានការអនុវត្តតាមខ្លឹមសារសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៩

រដ្ឋមន្ត្រី

ចាន់ សារុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ផែនការ
- ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួង ព័ត៌មាន
- ក្រសួង ពាណិជ្ជកម្ម
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់អង្គភាពក្រោមឱវាទក្រសួងដែលពាក់ព័ន្ធ
- គ្រប់មន្ទីរកសិកម្ម រាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ